# រ៉ូយ៉ាល់ រេលវេ ម.ក.

## របាយការណ៍ហិរញ្ញវត្ថុ
## សង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ
## 3ខែ និង 6ខែ ដែលបានបញ្ចប់
## ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023
## និង
## របាយការណ៍របស់សវនករឯករាជ្យ
## ស្តីពីការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ
## សង្ខេបចន្លោះពេល

# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ក្រុមហ៊ុន | រ៉ូយ៉ាល់ រេលវេ ម.ក. | |
| លេខបញ្ជីពាណិជ្ជកម្ម | 00018504 | |
| ទីស្នាក់ការចុះបញ្ជី | ស្ថានីយ៍រថភ្លើងភ្នំពេញ មហាវិថីសហព័ន្ធរុស្ស៊ី<br>សង្កាត់ស្រះចក ខណ្ឌដូនពេញ<br>រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | |
| ភាគទុនិក | អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា)<br>អ្នកឧកញ៉ា គិត ម៉េង | |
| ក្រុមប្រឹក្សាភិបាល | អ្នកឧកញ៉ា គិត ម៉េង | ប្រធានក្រុមប្រឹក្សាភិបាល |
| | លោក Raymond Thornton Yager | អភិបាល |
| | លោក William Mark Hanna | អភិបាល |
| | លោក Paul Clements | អភិបាល |
| | លោក លន់ យ៉េង | អភិបាលឯករាជ្យ |
| អ្នកគ្រប់គ្រង | លោក John Guiry | នាយកប្រតិបត្តិ |
| | លោកស្រី តូច សុធីតា | ប្រធានផ្នែកហិរញ្ញវត្ថុ |
| គណៈកម្មាធិការសវនកម្ម និងហានិភ័យ | លោក លន់ យ៉េង | ប្រធាន |
| | លោក Paul Clements | អភិបាល |
| | លោក William Mark Hanna | អភិបាល |
| គណកម្មាធិការតែងតាំង និងលាភការ | លោក William Mark Hanna | ប្រធាន |
| | លោក Paul Clements | អភិបាល |
| | លោក Raymond Thornton Yager | អភិបាល |
| ធនាគារិកចម្បង | ធនាគារវីង (ខេមបូឌា) ម.ក | |
| សវនករ | ខេភីអឹមជី ខេមបូឌា | |

**រ៉ូយ៉ាល់ ទេលេខ ម.ក.**

# មាតិកា


| | | ទំព័រ |
|---|---|---|
| 1. | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 – 6 |
| 2. | របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 7 – 9 |
| 3. | របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 10 – 11 |
| 4. | របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ សង្ខេបចន្លោះពេល | 12 – 13 |
| 5. | របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | 14 |
| 6. | របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល | 15 – 16 |
| 7. | កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | 17 – 59 |

**ROYAL RAILWAY PLC.**
Central Railway Station, Sangkat Sras Chork, Daun Penh, Phnom Penh, Cambodia
T +885 23 992 379
F +885 23 992 353
www.royal-railway.com

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល("អភិបាល") នៃរ៉ូយ៉ាល់ រេលវេ ម.ក. ("ក្រុមហ៊ុន") សូមធ្វើការដាក់បង្ហាញរបាយការណ៍របស់ខ្លួន និង របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបាន បញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺពាក់ព័ន្ធនឹងសេវាកម្មផ្លូវដែក ដែលរួមមានសេវាកម្មដឹកជញ្ជូនទំនិញ និងអ្នកដំណើរ តាមផ្លូវដែក ព្រមទាំងផ្តល់ជូននូវសេវាដឹកជញ្ជូនដោយមធ្យោបាយផ្សេងទៀត ក្នុងករណីដែលការដឹកជញ្ជូនតាម រថភ្លើងមិនអាចប្រព្រឹត្តិទៅបាន និងការថែរក្សាហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកនិងគ្រឿងបរិក្ខារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល។ សូមមើលទំព័រទី12 និង13។

## ភាគលាភ

ពុំមានការប្រកាសបែងចែក ឬទូទាត់ភាគលាភនៅក្នុងអំឡុងការិយបរិច្ឆេទនេះទេ ហើយក្រុមប្រឹក្សាភិបាលក៏មិនផ្តល់ អនុសាសន៍ឲ្យមានការទូទាត់ភាគលាភនាកាលបរិច្ឆេទនៃរបាយការណ៍នេះដែល។

## ដើមទុន

ពុំមានការផ្លាស់ប្តូររចនាសម្ព័ន្ធនៃការកាន់កាប់ដើមទុនក្នុងអំឡុងការិយបរិច្ឆេទ ដែលបានបញ្ចប់នេះទេ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុង របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

## រ៉ូយ៉ាល់ រេលវេ ម.ក.

### ការខាតបង់ដែលបានរំពឹងទុកទៅលើគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនត្រូវបានរៀបចំ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានាដើម្បីធ្វើឲ្យប្រាកដថា សកម្មភាពផ្សេងៗត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗត្រូវបានលុបចេញពីបញ្ជី ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ការខាតបង់ដែលបានរំពឹងទុកទៅលើគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចនឹងបណ្តាលឲ្យចំនួននៃគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗអាក្រក់ និងជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

### ទ្រព្យសកម្ម

នៅមុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមហេតុផលដើម្បីធ្វើឲ្យប្រាកដថា បណ្តាទ្រព្យសកម្មលើកលែងបំណុល ដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្ម តាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលបានរំពឹងទុកថាអាចប្រមូលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

### វិធីសាស្ត្រនៃការវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង បានធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានស្រាប់ ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

### បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ៖

- ពុំមានការផ្លាស់ប្តូរលើទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលបានយកមកប្រើប្រាស់សម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមក និង
- លើកលែងតែការបង្ហាញនៅក្នុងកំណត់សម្គាល់ 25 នៃរបាយការណ៍ហិរញ្ញវត្ថុ ពុំមានបំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

# រ៉ូយ៉ាល់ គ្រុប ម.ក.

## បំណុលយថាភាព និងបំណុលផ្សេងៗ (ត)

ក្រុមប្រឹក្សាភិបាលយល់ឃើញថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងទៀតរបស់ក្រុមហ៊ុន ដែលត្រូវបានទាមទារឲ្យសង ឬអាចនឹងទាមទារឲ្យសងក្នុងអំឡុងកាលបរិច្ឆេទ បន្ទាប់ពីចុងការិយបរិច្ឆេទនៃរបាយការណ៍នេះ ដែលនឹងបង្កឲ្យមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលដល់ថ្ងៃកំណត់នោះឡើយ។

## ការផ្លាស់ប្តូរនៃកាលៈទេសៈ

នាការិយបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានរែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទរបាយការណ៍ហិរញ្ញវត្ថុនេះ មិនរងផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីចុងការិយបរិច្ឆេទរាយការណ៍មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ព្រឹត្តិការណ៍ ឬធាតុណាមួយ ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតី ដែលអាចបណ្តាលឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទរាយការណ៍បច្ចុប្បន្ន ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍ក្នុងអំឡុងពេល និងចាប់តាំងពីកាលបរិច្ឆេទនៃការរាយការណ៍

គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 ក្រុមហ៊ុនពុំអាចអនុលោមបានតាមកិច្ចព្រមព្រៀងចំនួន 3 ចំនុចរួមមាន អនុបាតទូទាត់បំណុល អនុបាតប្រតិបត្តិការ និងអនុបាតបំណុលធៀបទៅនឹង EBITA ដែលបានកំណត់ក្រោមកិច្ចព្រមព្រៀងធានា។

ក្រុមហ៊ុនបានទាក់ទងទៅអ្នកធានាទៅលើចំនុចដែលមិនបានបំពេញខាងលើ នៅថ្ងៃទី13 ខែកក្កដា ឆ្នាំ2023 ហើយកំពុងស្ថិតក្នុងដំណើរការកែប្រែគំរូការព្យាករណ៍ហិរញ្ញវត្ថុរបស់ខ្លួន ផ្អែកតាមតម្រូវការរបស់អ្នកធានា។ ដោយឈរលើមូលដ្ឋាននៃការព្យាករណ៍ថ្មីរបស់ខ្លួន អ្នកគ្រប់គ្រងជឿជាក់នាពេលខាងមុខ ហានិភ័យដែលលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងនឹងមិនអាចបំពេញបាន គឺស្ថិតនៅក្នុងកម្រិតទាប។ នាថ្ងៃទី15 ខែសីហា ឆ្នាំ2023 ក្រុមហ៊ុនបានដាក់លិខិតសុំការលើកលែងពីការមិនអាចអនុលោមបានតាមតម្រូវការ ទៅកាន់អ្នកធានា និងកំពុងរង់ចាំការឆ្លើយតបត្រឡប់មកវិញ។ អាស្រ័យហេតុនេះ តម្លៃយោងនៃមូលបត្របំណុលមានការធានា ត្រូវបានចាត់ថ្នាក់ឡើងវិញទៅជាបំណុលរយៈពេលខ្លី។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលយល់ឃើញថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងអំឡុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះរួមមាន៖

| *ឈ្មោះ* | *តួនាទី* |
|---|---|
| អ្នកឧកញ៉ា គិត ម៉េង | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Raymond Thornton Yager | អភិបាល |
| លោក William Mark Hanna | អភិបាល |
| លោក Paul Clements | អភិបាល |
| លោក លន់ យ៉េង | អភិបាលឯករាជ្យ |

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ ពុំមានអភិបាលណាមួយកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនដោយផ្ទាល់ ឬដោយប្រយោល ក្រៅពីអ្នកឧកញ៉ា គិត ម៉េង ដែលជាប្រធានក្រុមប្រឹក្សាភិបាលមានកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុនដោយផ្ទាល់ផង និងដោយប្រយោលផង តាមរយៈក្រុមហ៊ុនអ៊ិនធើ ឡូជីស្ទីក (ខេមបូឌា)។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនៅចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានកិច្ចព្រមព្រៀងណាមួយដែលមានក្រុមហ៊ុនជាភាគីម្ខាងដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ បានផ្តល់លទ្ធភាពដល់សមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ក្រុមហ៊ុន ឬរបស់សាជីវកម្មដទៃទៀយ។

នៅក្នុងអំឡុងការិយបរិច្ឆេទ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលក្នុងចំនួនសរុប ដែលបានទទួល ឬដល់ពេលកំណត់ និងអាចទទួលបានដោយអភិបាល ដូចដែលបានដាក់បង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬជាមួយនឹងក្រុមហ៊ុនដែលមានអភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនណាមួយដែលអភិបាលនោះ មានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះឡើយ លើកលែងតែអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# រ៉ូយ៉ាល់ គ្រុប ម.ក.

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ក្រុមប្រឹក្សាភិបាល មានភារៈទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 និងសម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ ដូចបានបង្ហាញនៅទំព័រទី10 ដល់ទី59 ត្រូវបានរៀបចំឡើងជាសារវន្ត ដោយអនុលោមទៅតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល ("ស.គ.អ.ក 34")* ។ ក្រុមប្រឹក្សាភិបាល ត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដែលធ្វើឡើងដោយគណៈគ្រប់គ្រង ដែលត្រូវបានតម្រូវឲ្យ៖

- អនុម័តនូវគោលនយោបាយគណនេយ្យសមស្របនានា ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានយ៉ាងសមហេតុផល និងដោយភាពប្រុងប្រយ័ត្ន ហើយត្រូវអនុវត្តគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។
- អនុលោមតាមលក្ខខណ្ឌតម្រូវនៃការលាតត្រដាងព័ត៌មាន និងការណែនាំផ្សេងៗ ដែលចេញផ្សាយដោយស.គ.អ.ក 34 ឬប្រសិនបើមានវៀរចាកពីការបង្ហាញព័ត៌មានដ៏សមស្រប គឺត្រូវធ្វើឲ្យប្រាកដថា ការវៀរចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឲ្យបានសមស្របក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។
- រក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែវាមានភាពមិនសមរម្យក្នុងការសន្មតថា ក្រុមហ៊ុននឹងអាចបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននាពេលអនាគតបាន។
- បង្កើតគោលការណ៍ជារួមសម្រាប់ក្រុមហ៊ុន អនុម័តរាល់សេចក្តីសម្រេច និងសកម្មភាពទាំងឡាយធ្វើឡើងដោយគណៈគ្រប់គ្រង ដែលមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ហើយត្រូវធានាថាគោលនយោបាយ និងសេចក្តីសម្រេចទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវក្នុងការរក្សាទុកបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវ រួមទាំងភាពច្បាស់លាស់នៃបញ្ជីនេះ នៅគ្រប់ពេលវេលា ដែលបង្ហាញពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងត្រូវធានាថា បញ្ជីគណនេយ្យបានអនុលោមតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រងក៏មានភារៈទទួលខុសត្រូវផងដែរចំពោះការការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន និងចាត់វិធានការសមស្របនានា ដើម្បីទប់ស្កាត់ និងស្វែងរកការក្លែងបន្លំ និងភាពមិនប្រក្រតី។

ក្រុមប្រឹក្សាភិបាលបានអះអាងថា គណៈគ្រប់គ្រងបានអនុវត្តតាមលក្ខខណ្ឌតម្រូវខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

ខ្ញុំបាទ ជាតំណាងឲ្យក្រុមប្រឹក្សាភិបាលនៃ រ៉ូយ៉ាល់ រេលវេ ម.ក. សូមជូនមតិថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល រួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយត្រូវបានរៀបចំឡើងគ្រប់ទិដ្ឋភាពជាសារវន្ត ដោយអនុលោមទៅតាម ស.គ.អ.ក 34 *របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល*។

*ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល៖*

អ្នកឧកញ៉ា គិត ម៉េង
*ប្រធានក្រុមប្រឹក្សាភិបាល*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី 30 ខែសីហា ឆ្នាំ2023

KPMG

KPMG Cambodia Ltd
GIA Tower, Sopheak Mongkul Street, Phum 14
Sangkat Tonle Bassac, Khan Chamkar Mon
Phnom Penh, Cambodia
+855 (17) 666 537 / +855 (81) 533 999 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យស្តីពីការត្រួតពិនិត្យលើ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល

## ជូនចំពោះភាគទុនិករបស់ រ៉ូយ៉ាល់ រេលវេ ម.ក.

### *សេចក្តីផ្តើម*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 របស់ក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ ម.ក. ហៅកាត់ថា ("ក្រុមហ៊ុន") ដូចបានបង្ហាញនៅទំព័រទី10 ដល់ទី59 ជារួមហៅកាត់ថា ("របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល") ដែលរួមមានៈ

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2023
- របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023
- របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023
- របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023និង
- កំណត់សម្គាល់ពន្យល់ផ្សេងៗទៀតទៅលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងបង្ហាញនូវភាពត្រឹមត្រូវនៃ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *"របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល"*។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺផ្តល់ការសន្និដ្ឋានលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយផ្អែកលើការធ្វើការត្រួតពិនិត្យរបស់យើងខ្ញុំ។

KPMG Cambodia Ltd., a Cambodian single member private limited company and a member firm of the KPMG global organization of independent member firms affiliated with KPMG International Limited, a private English company limited by guarantee. All rights reserved.

## *វិសាលភាពនៃការត្រួតពិនិត្យ*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមទៅតាមស្តង់ដាអន្តរជាតិនៃកម្ពុជាសម្រាប់កិច្ចការងារត្រួតពិនិត្យលេខ 2410 ស្តីពី"*ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន*"។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល រួមមានការសាកសួរព័ត៌មានជាពិសេសសាកសួរបុគ្គលដែលមានភារៈទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុ ហើយធ្វើការវិភាគ និងអនុវត្តនូវនីតិវិធីត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យ មានវិសាលភាពតូចជាងការធ្វើសវនកម្ម ដែលអនុលោមតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ហេតុដូច្នេះ ការត្រួតពិនិត្យមិនអាចឲ្យយើងខ្ញុំ ផ្តល់នូវអំណះអំណាងថា យើងខ្ញុំបានដឹងនូវរាល់បញ្ហាជាសារវន្តទាំងឡាយ ដែលអាចនឹងត្រូវបានរកឃើញក្នុងពេលធ្វើសវនកម្មនោះឡើយ។ ហេតុដូច្នេះយើងខ្ញុំ មិនបញ្ចេញមតិសវនកម្មនោះទេ។

## *ការទាញចំណាប់អារម្មណ៍លើបញ្ហា*

យើងខ្ញុំ សូមធ្វើការទាញចំណាប់អារម្មណ៍លើកំណត់សម្គាល់ 25.1 នៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលបញ្ជាក់អំពីកម្រៃសម្បទានត្រូវបង់ទៅរាជរដ្ឋាភិបាលកម្ពុជា តាមកិច្ចព្រមព្រៀងសម្បទានដែលមានស្រាប់ សម្រាប់ការប្រើប្រាស់ទ្រព្យសម្បទាន ចាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងសម្បទាន។ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនបានធ្វើការវាយតម្លៃលើកាតព្វកិច្ចរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងសម្បទានដែលមានស្រាប់ ហើយជឿជាក់ថាកាតព្វកិច្ចក្នុងការទូទាត់ថ្លៃសម្បទាននេះពុំទាន់មានប្រសិទ្ធភាពនៅឡើយទេ។ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនកំពុងបន្តការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជា ទៅលើវិសោធនកម្មកិច្ចព្រមព្រៀងសម្បទានថ្មី។ អ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនជឿជាក់ថា ចំនួន និងពេលវេលានៃលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចនៅមិនទាន់អាចប៉ាន់ស្មានដោយជឿជាក់បាន ដោយសារតែកាលបរិច្ឆេទមានប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងសម្បទានមិនត្រូវបានកំណត់នៅឡើយ គិតត្រឹមកាលបរិច្ឆេទរបាយការណ៍នេះ។ លទ្ធផលចុងក្រោយនៃបញ្ហានេះ គឺមានលក្ខណៈមិនប្រាកដប្រជា អាស្រ័យហេតុនេះ ពុំមានបំណុលសំវិធានធនណាមួយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលទេ។

## *បញ្ហាផ្សេងៗ*

យើងខ្ញុំ សូមធ្វើការទាញចំណាប់អារម្មណ៍ថា យើងខ្ញុំមិនបានត្រួតពិនិត្យទៅលើរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ របាយការណ៍បម្រែបម្រួលមូលធនសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់និងកំណត់សម្គាល់ ពាក់ព័ន្ធនឹងព័ត៌មានពន្យល់ផ្សេងៗ ដូច្នេះយើងខ្ញុំពុំផ្តល់ការសន្និដ្ឋាន ឬអំណះអំណាងណាមួយទៅលើព័ត៌មានដែលបានរៀបរាប់ខាងលើនោះឡើយ។

KPMG

## *សេចក្តីសន្និដ្ឋាន*

ផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ ពុំមានបញ្ហាណាមួយដែលបានទាញចំណាប់អារម្មណ៍យើងខ្ញុំ ដែលបណ្តាលឲ្យយើងខ្ញុំជឿថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនត្រូវបានរៀបចំជាសារវន្ត ស្របតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 *"របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"* នោះឡើយ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**

ព្រះរាជាណាចក្រកម្ពុជា
ខេ ភី អឹម ជី ខេមបូឌា
KPMG CAMBODIA LTD.
ទីស្នាក់ការរាជធានីភ្នំពេញ

**តាំង យុកហុង**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី30 ខែសីហា ឆ្នាំ2023

# រ៉ូយ៉ាល់ គ្រុប ភីអិលស៊ី

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

| | កំណត់សម្គាល់ | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 ដុល្លារអាមេរិក | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 ពាន់រៀល (កំណត់សម្គាល់ 4) | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ដុល្លារអាមេរិក | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 ពាន់រៀល (កំណត់សម្គាល់ 4) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សាច់ប្រាក់ និងសមតុល្យនៅធនាគារ | 5 | 20,548,186 | 84,864,008 | 23,981,297 | 98,731,000 |
| គណនីអតិថិជន និង គណនីត្រូវទទួលផ្សេងៗ | 6 | 2,353,727 | 9,720,892 | 2,370,718 | 9,760,246 |
| សន្និធិ | 7 | 171,449 | 708,084 | 214,835 | 884,476 |
| | | 23,073,362 | 95,292,984 | 26,566,850 | 109,375,722 |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| សមតុល្យនៅធនាគារ | 5 | 3,864,400 | 15,959,972 | 3,773,687 | 15,536,269 |
| ទ្រព្យ និងបរិក្ខារ | 8 | 7,817,522 | 32,286,366 | 7,007,931 | 28,851,652 |
| ទ្រព្យសកម្មអរូបី | 9 | 252,327 | 1,042,111 | 259,621 | 1,068,860 |
| ទ្រព្យវិនិយោគ | 10 | 36,379 | 150,245 | - | - |
| | | 11,970,628 | 49,438,694 | 11,041,239 | 45,456,781 |
| **ទ្រព្យសកម្មសរុប** | | 35,043,990 | 144,731,678 | 37,608,089 | 154,832,503 |
| **បំណុល និងមូលធន** | | | | | |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ និង គណនីត្រូវទូទាត់ផ្សេងៗ | 11 | 1,868,426 | 7,716,599 | 3,741,073 | 15,401,998 |
| ប្រាក់កម្ចី | 12 | 1,833,287 | 7,571,475 | 1,782,400 | 7,338,141 |
| មូលបត្របំណុល | 13 | 24,434,573 | 100,914,786 | 233,763 | 962,402 |
| បំណុលលើអត្ថប្រយោជន៍និយោជិត | 14 | 95,505 | 394,436 | 86,391 | 355,672 |
| បំណុលពន្ធអប្បបរមា | 21(ខ) | 9,764 | 40,325 | 66,007 | 271,751 |
| | | 28,241,555 | 116,637,621 | 5,909,634 | 24,329,964 |

# ធនាគារ រ៉ូយ៉ាល់ ឡែនកូ ម.ក.

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

| | | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| **បំណុលរយៈពេលវែង** | | | | | |
| មូលបត្របំណុល | 13 | 9,809,327 | 40,512,521 | 33,051,243 | 136,071,967 |
| ប្រាក់កម្ចី | 12 | 755,541 | 3,120,384 | 855,227 | 3,520,970 |
| សំវិធានធនលើកិច្ចសន្យាខាតបង់ | | 52,308 | 216,032 | - | - |
| បំណុលលើអត្ថប្រយោជន៍និយោជិត | 14 | 53,291 | 220,092 | 61,693 | 253,990 |
| | | 10,670,467 | 44,069,029 | 33,968,163 | 139,846,927 |
| **បំណុលសរុប** | | 38,912,022 | 160,706,650 | 39,877,797 | 164,176,891 |
| **មូលធន** | | | | | |
| ដើមទុន | 15 | 13,020,930 | 52,083,720 | 13,020,930 | 52,083,720 |
| ប្រាក់ខាតបង្គរ | | (16,888,962) | (68,761,198) | (15,290,638) | (62,217,661) |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | - | 702,506 | - | 789,553 |
| | | (3,868,032) | (15,974,972) | (2,269,708) | (9,344,388) |
| **បំណុល និងមូលធនសរុប** | | 35,043,990 | 144,731,678 | 37,608,089 | 154,832,503 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| | | | | *(មិនត្រូវបានត្រួតពិនិត្យ)* | |
| ចំណូល | 16 | 5,361,399 | 21,949,568 | 5,590,044 | 22,695,579 |
| ថ្លៃដើមសេវាកម្ម | 17 | (6,142,949) | (25,149,233) | (6,272,005) | (25,464,340) |
| **ប្រាក់ខាតដុល** | | (781,550) | (3,199,665) | (681,961) | (2,768,761) |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | 18 | 800,542 | 3,277,419 | 233,558 | 948,245 |
| ចំណូល/(ចំណាយ) ប្រតិបត្តិការ និងរដ្ឋបាល | 19 | 618,518 | 2,532,213 | (968,997) | (3,934,128) |
| ចំណាយសំវិធានធន លើកិច្ចសន្យាខាតបង់ | | (52,308) | (214,149) | - | - |
| ការកត់ត្រឡប់មកវិញ/(សំវិធានធន) សម្រាប់ការខាតបង់ឱនភាពនៃតម្លៃ | 5,6 | 18,559 | 75,981 | (9,331) | (37,884) |
| ចំណាយពន្ធអប្បបរមា | 21(គ) | (62,268) | (254,925) | (58,300) | (236,698) |
| **ប្រាក់ចំណេញ/(ប្រាក់ខាត)ពីប្រតិបត្តិការ** | | 541,493 | 2,216,874 | (1,485,031) | (6,029,226) |
| ចំណាយហិរញ្ញប្បទាន – សុទ្ធ | 22 | (2,139,817) | (8,760,411) | (65,776) | (267,050) |
| **ប្រាក់ខាតមុនដកពន្ធ លើប្រាក់ចំណេញ** | | (1,598,324) | (6,543,537) | (1,550,807) | (6,296,276) |
| ចំណាយពន្ធលើប្រាក់ចំណេញ | 21(គ) | - | - | - | - |
| **ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | (1,598,324) | (6,543,537) | (1,550,807) | (6,296,276) |
| *លទ្ធផលលម្អិតផ្សេងៗ* | | | | | |
| **ធាតុដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញ ក្នុងរបាយការណ៍ចំណេញ ឬខាត** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (87,047) | - | (22,904) |
| **ប្រាក់ខាតលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ** | | (1,598,324) | (6,630,584) | (1,550,807) | (6,319,180) |

# រ៉ូយ៉ាល់ រេលវេ ម.ក.

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| | | | | *(មិនត្រូវបានត្រួតពិនិត្យ)* | |
| ចំណូល | 16 | 2,666,892 | 10,944,925 | 2,613,964 | 10,602,238 |
| ថ្លៃដើមសេវាកម្ម | 17 | (3,051,240) | (12,522,289) | (3,293,898) | (13,360,050) |
| **ប្រាក់ខាតដុល** | | (384,348) | (1,577,364) | (679,934) | (2,757,812) |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | 18 | 449,647 | 1,845,351 | 78,813 | 319,666 |
| ចំណាយប្រតិបត្តិការ និងរដ្ឋបាល | 19 | (652,281) | (2,676,961) | (508,660) | (2,063,125) |
| ចំណាយសំវិធានធន លើកិច្ចសន្យាខាតបង់ | | (52,308) | (214,672) | - | - |
| សំវិធានធនសម្រាប់ការខាតបង់ ឱនភាពនៃតម្លៃ | 5,6 | (1,655) | (6,792) | (1,629) | (6,607) |
| ចំណាយពន្ធអប្បបរមា | 21(គ) | (31,226) | (128,152) | (26,918) | (109,179) |
| **ប្រាក់ខាតប្រតិបត្តិការ** | | (672,171) | (2,758,590) | (1,138,328) | (4,617,057) |
| ចំណាយហិរញ្ញប្បទាន – សុទ្ធ | 22 | (1,271,968) | (5,220,157) | (32,921) | (133,528) |
| **ប្រាក់ខាតមុនដកពន្ធ លើប្រាក់ចំណេញ** | | (1,944,139) | (7,978,747) | (1,171,249) | (4,750,585) |
| ចំណាយពន្ធលើប្រាក់ចំណេញ | 21(គ) | - | - | - | - |
| **ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | (1,944,139) | (7,978,747) | (1,171,249) | (4,750,585) |
| *លទ្ធផលលម្អិតផ្សេងៗ* | | | | | |
| **ធាតុដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញ ក្នុងរបាយការណ៍ចំណេញ ឬខាត** | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (50,547) | - | (16,398) |
| **ប្រាក់ខាតលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ** | | (1,944,139) | (8,029,294) | (1,171,249) | (4,766,983) |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# រ៉ូយ៉ាល់ គ្រុប ផ្នំពេញ ស.ក.

## របាយការណ៍ស្ដីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

| | ដើមទុន | | ប្រាក់ខាតបង្គរ | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2023 | 13,020,930 | 52,083,720 | (15,290,638) | (62,217,661) | - | 789,553 | (2,269,708) | (9,344,388) |
| *លទ្ធផលលម្អិតសរុប* | | | | | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | (1,598,324) | (6,543,537) | - | - | (1,598,324) | (6,543,537) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (87,047) | - | (87,047) |
| | - | - | (1,598,324) | (6,543,537) | - | (87,047) | (1,598,324) | (6,630,584) |
| នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | 13,020,930 | 52,083,720 | (16,888,962) | (68,761,198) | - | 702,506 | (3,868,032) | (15,974,972) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2022 | 13,020,930 | 52,083,720 | (11,172,067) | (45,385,061) | - | 833,609 | 1,848,863 | 7,532,268 |
| *លទ្ធផលលម្អិតសរុប* | | | | | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ *(មិនត្រូវបានត្រួតពិនិត្យ)* | - | - | (1,550,807) | (6,296,276) | - | - | (1,550,807) | (6,296,276) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (22,904) | - | (22,904) |
| | - | - | (1,550,807) | (6,296,276) | - | (22,904) | (1,550,807) | (6,319,180) |
| នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 *(មិនត្រូវបានត្រួតពិនិត្យ)* | 13,020,930 | 52,083,720 | (12,722,874) | (51,681,337) | - | 810,705 | 298,056 | 1,213,088 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# រ៉ូយ៉ាល់ គ្រុប ភ្នំពេញ អេសអ៊ីហ្សេដ ម.ក (header approx)

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

| | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| | | | *(មិនត្រូវបានត្រួតពិនិត្យ)* | |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | (1,598,324) | (6,543,537) | (1,550,807) | (6,296,276) |
| *និយ័តភាពលើ៖* | | | | |
| រំលស់ | 601,219 | 2,461,390 | 492,038 | 1,997,674 |
| ចំណាយហិរញ្ញប្បទាន | 2,346,506 | 9,606,596 | 65,887 | 267,501 |
| អត្ថប្រយោជន៍និយោជិត | 101,002 | 413,502 | 91,867 | 372,980 |
| ការលុបចោលទ្រព្យ និងបរិក្ខារ | 17,286 | 70,769 | - | - |
| ចំណាយពន្ធអប្បបរមា | 62,268 | 254,925 | 58,300 | 236,698 |
| ចំណូលហិរញ្ញប្បទាន | (206,689) | (846,185) | (111) | (451) |
| ចំណាយសំវិធានធន លើកិច្ចសន្យាខាតបង់ | 52,308 | 214,149 | - | - |
| (ការកត់ត្រឡប់មកវិញ)/សំវិធានធន សម្រាប់ការខាតបង់ឱនភាពនៃតម្លៃ | (18,559) | (75,981) | 9,331 | 37,884 |
| | 1,357,017 | 5,555,628 | (833,495) | (3,383,990) |
| *បម្រែបម្រួលនៃ៖* | | | | |
| គណនីអតិថិជន និង គណនីត្រូវទទួលផ្សេងៗ | 2,592 | 10,612 | 25,275 | 102,617 |
| សន្និធិ | (85,829) | (351,384) | (40,204) | (163,228) |
| គណនីអ្នកផ្គត់ផ្គង់ និង គណនីត្រូវទូទាត់ផ្សេងៗ | (1,872,647) | (7,666,617) | (406,841) | (1,651,774) |
| សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ | (598,867) | (2,451,761) | (1,255,265) | (5,096,375) |
| ការប្រាក់បានបង់ | (1,380,759) | (5,652,827) | (65,887) | (267,501) |
| ការទូទាត់អត្ថប្រយោជន៍និយោជិត | (100,290) | (410,587) | (71,656) | (290,923) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (118,511) | (485,184) | (59,849) | (242,987) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពប្រតិបត្តិការ** | (2,198,427) | (9,000,359) | (1,452,657) | (5,897,786) |

# រ៉ូយ៉ាល់ គ្រុប ម.ក.

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

| | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | សម្រាប់ដំណាច់ ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| | | | *(មិនត្រូវបានត្រួតពិនិត្យ)* | |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការប្រាក់បានទទួល | 115,976 | 474,806 | 111 | 451 |
| ការទិញទ្រព្យ និងបរិក្ខារ | (1,326,766) | (5,431,780) | (1,255,298) | (5,096,510) |
| ការទិញទ្រព្យសកម្មអរូបី | (1,200) | (4,913) | - | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ** | (1,211,990) | (4,961,887) | (1,255,187) | (5,096,059) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់បានពីប្រាក់កម្ចី | - | - | 4,000,000 | 16,240,000 |
| ការទូទាត់ប្រាក់កម្ចី | (55,652) | (227,839) | (1,181,599) | (4,797,292) |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | (55,652) | (227,839) | 2,818,401 | 11,442,708 |
| **(ការថយចុះ)/កើនឡើងសុទ្ធនៃ សាច់ប្រាក់ និងសាច់ប្រាក់សមមូល** | (3,466,069) | (14,190,085) | 110,557 | 448,863 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ** | 24,191,824 | 99,597,739 | 121,766 | 496,075 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | 189,714 | - | 616 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** (កំណត់សម្គាល់ 5) | 20,725,755 | 85,597,368 | 232,323 | 945,554 |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ គឺជាផ្នែកមួយ និងត្រូវអានភ្ជាប់ជាមួយរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ។

### 1. ព័ត៌មានទូទៅ

រ៉ូយ៉ាល់ រេលវេ ម.ក. ហៅកាត់ថា ("ក្រុមហ៊ុន") ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងនៅព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនត្រូវបានបង្កើតឡើងដំបូង ក្រោមលេខបញ្ជីពាណិជ្ជកម្ម Co. 2874/06E ចុះថ្ងៃទី6 ខែមេសា ឆ្នាំ2006 ចេញដោយក្រសួងពាណិជ្ជកម្ម។ បន្ទាប់មកក្រុមហ៊ុនបានទទួលការអនុម័តពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីក្លាយជាគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ("QIP") ដែលមានលេខចុះបញ្ជីថ្មី 0643KH/2014 ចុះថ្ងៃទី6 ខែតុលា ឆ្នាំ2015។ នៅថ្ងៃទី25 ខែសីហា ឆ្នាំ2016 ក្រុមហ៊ុនបានចុះបញ្ជីឡើងវិញ និងទទួលលេខបញ្ជីពាណិជ្ជកម្មថ្មីគឺ 00018504 ពីក្រសួងពាណិជ្ជកម្ម។

ក្រុមហ៊ុនដំណើរការសេវាកម្មផ្លូវដែកក្រោម កិច្ចព្រមព្រៀងសម្បទានផ្លូវដែក ("កិច្ចព្រមព្រៀងសម្បទាន") ជាមួយរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីផ្តល់សេវាកម្មផ្លូវដែកនៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល 30ឆ្នាំ ទៅលើទ្រព្យសកម្មសម្បទានជាក់លាក់ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។ ប៉ុន្តែកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងសម្បទាន គឺមិនទាន់បានកំណត់ជាផ្លូវការនោះទេ ដោយសារតែលក្ខខណ្ឌមុនកាលបរិច្ឆេទចូលជាធរមាននៅពុំទាន់បានបំពេញទាំងស្រុងនៅឡើយ។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមហ៊ុននៅតែបន្តធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើវិសោធនកម្មកិច្ចព្រមព្រៀងសម្បទានផ្លូវដែកថ្មី។

ភាគហ៊ុនរបស់ក្រុមហ៊ុន 98.9999% ជាកម្មសិទ្ធិរបស់ក្រុមហ៊ុន អ៊ិនធើ ឡូជីស្ទីក (ខេមបូឌា) និង 1.0001% ទៀតជាកម្មសិទ្ធិរបស់អ្នកឧកញ៉ា គិត ម៉េង។

ការិយាល័យដែលបានចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅស្ថានីយ៍ផ្លូវដែកកណ្តាល មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 ក្រុមហ៊ុនមានបុគ្គលិកចំនួន 828 នាក់ (នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2022៖ មានបុគ្គលិកចំនួន 717 នាក់)។

## រ៉ូយ៉ាល់ គ្រុប ផ្នូ ម.ក.

### កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
### សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

## 2. មូលដ្ឋានទូទៅនៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ("ស.គ.អ.ក") 34 *"របាយការណ៍ហិរញ្ញវត្ថុចន្លោះពេល"* ។ របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល មិនបានរួមបញ្ចូលនូវរាល់ព័ត៌មានទាំងស្រុងរបស់របាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជានោះទេ។ យ៉ាងណាមិញ កំណត់សម្គាល់ពន្យល់បន្ថែមដែលបានជ្រើសរើស ត្រូវបានដាក់បញ្ចូលដើម្បីពន្យល់ពីព្រឹត្តិការណ៍ និងប្រតិបត្តិការទាំងឡាយដែលមានលក្ខណៈជាសារវន្ត ក្នុងការស្វែងយល់ពីបម្រែបម្រួលនៃស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលរបស់ក្រុមហ៊ុនចាប់តាំងពីរបាយការណ៍ហិរញ្ញវត្ថុចុងក្រោយនាកាលបរិច្ឆេទ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ត្រូវបានអនុម័ត និងផ្តល់សិទ្ធិបោះផ្សាយដោយក្រុមប្រឹក្សាភិបាល នៅថ្ងៃទី30 ខែសីហា ឆ្នាំ2023។

### (ខ) គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលត្រូវបានយកមកអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល គឺដូចគ្នាទៅនឹងគោលនយោបាយដែលបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2022។

### (គ) ការសន្មតនិរន្តរភាពអាជីវកម្ម

នៅក្នុងដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 ក្រុមហ៊ុនមានប្រាក់ខាតសុទ្ធចំនួន 1,598,324 ដុល្លារអាមេរិក (ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 (មិនត្រូវបានត្រួតពិនិត្យ)៖ ប្រាក់ខាតសុទ្ធចំនួន 1,550,807 ដុល្លារអាមេរិក) និងមានសាច់ប្រាក់អវិជ្ជមានពីសកម្មភាពប្រតិបត្តិការសុទ្ធចំនួន 2,198,427 ដុល្លារអាមេរិក (ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 (មិនត្រូវបានត្រួតពិនិត្យ)៖ 1,452,657 ដុល្លារអាមេរិក) និង គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 ក្រុមហ៊ុនមាន បំណុលរយៈពេលខ្លីសុទ្ធចំនួន 17,571,088 ដុល្លារអាមេរិក (គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2023៖ ទ្រព្យសកម្មរយៈពេលខ្លីសុទ្ធ 21,111,382 ដុល្លារអាមេរិក) ហើយ មានប្រាក់ខាតបង្គរចំនួន 16,888,962 ដុល្លារអាមេរិក (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022៖ 15,290,638 ដុល្លារអាមេរិក)។

## វិញ្ញាបនបត្រ/កំណត់សម្គាល់ ម.ក.

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

### 2. មូលដ្ឋានទូទៅនៃការរៀបចំ (ត)

#### (គ) ការសន្មតនិរន្តរភាពអាជីវកម្ម (ត)

សុពលភាពនៃការសន្មតនិរន្តភាពអាជីវកម្មជាមូលដ្ឋាន គឺអាស្រ័យទៅលើការបន្តផ្តល់ជំនួយហិរញ្ញវត្ថុរបស់ភាគទុនិកធំដែលចាំបាច់ដើម្បីឲ្យក្រុមហ៊ុនអាចមានលទ្ធភាពក្នុងការទូទាត់បំណុលរបស់ខ្លួន នៅពេលដល់កំណត់ដែលត្រូវទូទាត់សង និងដើម្បីរក្សានិរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុននាពេលអនាគត។ នាកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ភាគទុនិកបានបញ្ជាក់ពីការគាំទ្រផ្នែកហិរញ្ញវត្ថុឲ្យបានគ្រប់គ្រាន់បន្តទៀតដល់ក្រុមហ៊ុន ហើយពុំមានហេតុផលណាមួយដែលអាចឲ្យអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនជឿជាក់ថា ភាគទុនិកនឹងមិនបន្តការគាំទ្រដល់ក្រុមហ៊ុននោះទេ។

#### (ឃ) ការប្រើប្រាស់ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ អ្នកគ្រប់គ្រងបានធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែង អាចខុសពីការប៉ាន់ស្មានទាំងនោះ។

ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ប្រមាណត្រូវបានទទួលស្គាល់តាមវិធីសាស្ត្រទស្សនវិស័យ។

### 3. រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល។ ដោយសារក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រងក៏បានកំណត់ថាប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលទាំងនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ចំនួនទាំងអស់ត្រូវបានបង្គត់ទៅដុល្លារអាមេរិកដែលនៅជិតបំផុត លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

### 4. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក។ ការប្តូររូបិយប័ណ្ណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិក ទៅជាប្រាក់រៀល បានបំពេញតាមលក្ខខណ្ឌតម្រូវនៃការបង្ហាញព័ត៌មានដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយការប្តូររូបិយប័ណ្ណនេះ ធ្វើឡើងដោយអនុលោមទៅតាមស.គ.អ .ក 21 – *ឥទ្ធិពលនៃការប្រែប្រួលអត្រាប្តូររូបិយប័ណ្ណបរទេស*។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រានាកាលបរិច្ឆេទរាយការណ៍ ហើយដើមទុន និងគណនីមូលធនផ្សេងៗត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្ត្រ។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរទឹកប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យម នៅក្នុងការិយបរិច្ឆេទរាយការណ៍ ដែលអត្រានេះត្រូវបានចាត់ទុកថាមានកម្រិតប្រហាក់ប្រហែលទៅនឹងអត្រាប្តូររូបិយប័ណ្ណនាថ្ងៃប្រតិបត្តិការ ដោយសារតែអត្រាប្តូររូបិយប័ណ្ណមិនមានការប្រែប្រួលជាសារវន្តនៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា"លម្អៀងពីការប្តូររូបិយប័ណ្ណ"នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូរប្រាក់ដូចខាងក្រោម៖

| **ការិយបរិច្ឆេទហិរញ្ញវត្ថុ** | | **អត្រានាកាលបរិច្ឆេទរាយការណ៍** | **អត្រាមធ្យមការិយបរិច្ឆេទ 6ខែ** | **អត្រាមធ្យមការិយបរិច្ឆេទ 3ខែ** |
|---|---|---|---|---|
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | 1 ដុល្លារអាមេរិក= | 4,130 រៀល | 4,094 រៀល | 4,104 រៀល |
| ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 | 1 ដុល្លារអាមេរិក= | 4,070 រៀល | 4,060 រៀល | 4,056 រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | 1 ដុល្លារអាមេរិក= | 4,117 រៀល | មិនមាន | មិនមាន |

ការកែសម្រួលនេះ មិនគួរត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិកនេះត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

## 5. សាច់ប្រាក់ និងសមតុល្យនៅធនាគារ

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| *រយៈពេលខ្លី* | | | | |
| សាច់ប្រាក់ក្នុងដៃ | 3,058 | 12,629 | 5,538 | 22,800 |
| សាច់ប្រាក់ក្នុងធនាគារ (*) | 20,722,697 | 85,584,739 | 24,186,286 | 99,574,939 |
| សាច់ប្រាក់ និងសមតុល្យ នៅធនាគារសរុប | 20,725,755 | 85,597,368 | 24,191,824 | 99,597,739 |
| ដកៈ សំវិធានធនលើឱនភាពនៃតម្លៃ | (177,569) | (733,360) | (210,527) | (866,739) |
| | 20,548,186 | 84,864,008 | 23,981,297 | 98,731,000 |
| *រយៈពេលវែង* | | | | |
| សាច់ប្រាក់ក្នុងធនាគារៈ | | | | |
| គណនីបម្រុងសេវាបំណុល ("DSRA") (**) | 3,505,895 | 14,479,346 | 3,423,595 | 14,094,940 |
| គណនីបម្រុងសេវាធានា ("GFRA") (**) | 358,505 | 1,480,626 | 350,092 | 1,441,329 |
| សមតុល្យនៅធនាគារសរុប | 3,864,400 | 15,959,972 | 3,773,687 | 15,536,269 |

(*) សមតុល្យសាច់ប្រាក់នៅធនាគារនេះ បានរួមបញ្ចូលទាំងគណនីសាច់ប្រាក់ពីមូលបត្របំណុល។ ក្រុមហ៊ុននឹងអាចដកទឹកប្រាក់ពីគណនីនេះ បន្ទាប់ពីធ្វើការដាក់សំណើជាលាយលក្ខណ៍អក្សរសម្រាប់ការចំណាយលើដើមទុនជាក់លាក់ និងត្រូវមានការអនុម័ត្រដោយ Guarant.Co Ltd ("អ្នកធានា")។ ទោះជាយ៉ាងណាគណនីនេះនៅតែសន្និដ្ឋានថាជាប្រាក់បញ្ញើតាមតម្រូវការ ដែលបានបំពេញតាមនិយមន័យសាច់ប្រាក់របស់ស.រ.ហ.អ.ក។ នាថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 ចំនួនទឹកប្រាក់ដែលមាននៅក្នុងគណនីមានចំនួន 18,756,694 ដុល្លារអាមេរិក (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022៖ 19,802,402 ដុល្លារអាមេរិក)។

(**) គណនីបម្រុងសេវាបំណុល និងគណនីបម្រុងសេវាធានា គឺជាគណនីបម្រុងដែលបានកំណត់សម្រាប់ការទូទាត់បំណុល និងការទូទាត់ថ្លៃសេវាធានា ក្នុងករណីមានការខកខាននៃលំហូរទឹកប្រាក់សម្រាប់ទូទាត់លើមូលបត្របំណុល (តួយ៉ាង ព្រឹត្តិការណ៍នៃការខាតបង់) ហើយវាត្រូវបានរក្សាទុកនៅធនាគារអេស៊ីលីដា ដែលទទួលបានអត្រាការប្រាក់ 5.00%ក្នុងមួយឆ្នាំ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022៖ 5%) និងត្រូវរក្សាទុកជាសមតុល្យអប្បបរមាសម្រាប់រយៈពេលនៃមូលបត្របំណុល។

# រ៉ូយ៉ាល់ រេលវេ ម.ក.

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

### 5. សាច់ប្រាក់ និងសមតុល្យនៅធនាគារ (ត)

សម្រាប់គោលបំណងនៃការរៀបចំរបាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានដូចខាងក្រោមៈ

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| | | | *(មិនត្រូវបានត្រួតពិនិត្យ)* | |
| សាច់ប្រាក់ក្នុងដៃ | 3,058 | 12,629 | 6,092 | 24,794 |
| សាច់ប្រាក់ក្នុងធនាគារ (រយៈពេលខ្លី) | 20,722,697 | 85,584,739 | 226,231 | 920,760 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | 20,725,755 | 85,597,368 | 232,323 | 945,554 |

## 5. សាច់ប្រាក់ និងសមតុល្យនៅធនាគារ (ត)

បម្រែបម្រួលនៃសំវិធានធនលើឱនភាពនៃតម្លៃសម្រាប់សមតុល្យនៅធនាគារក្នុងអំឡុងការិយបរិច្ឆេទ មានដូចខាងក្រោម៖

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ | | | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 | | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| | | | *(មិនត្រូវបានត្រួតពិនិត្យ)* | | | | *(មិនត្រូវបានត្រួតពិនិត្យ)* | |
| សមតុល្យដើមការិយបរិច្ឆេទ | (210,527) | (866,739) | - | - | (197,058) | (798,873) | (1,399) | (5,665) |
| ទទួលស្គាល់ក្នុងរបាយការណ៍ ចំណេញ ឬខាត | 32,958 | 134,930 | (2,477) | (10,057) | 19,489 | 79,983 | (1,078) | (4,373) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (1,551) | - | (24) | - | (14,470) | - | (43) |
| សមតុល្យចុងការិយបរិច្ឆេទ | (177,569) | (733,360) | (2,477) | (10,081) | (177,569) | (733,360) | (2,477) | (10,081) |

# វីយ៉ាល់ អេលធេ ម.ក.

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

### 6. គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| គណនីអតិថិជន | 646,795 | 2,671,263 | 545,610 | 2,246,276 |
| ដកៈ សំវិធានធនលើឱនភាពនៃតម្លៃ | (115,571) | (477,308) | (101,172) | (416,525) |
| | 531,224 | 2,193,955 | 444,438 | 1,829,751 |
| បុរេប្រទានទៅអ្នកផ្គត់ផ្គង់ | 1,621,381 | 6,696,304 | 1,696,781 | 6,985,647 |
| គណនីត្រូវទទួលពីសម្ព័ន្ធញាតិ (កំណត់សម្គាល់ 23) | 47,916 | 197,893 | 53,094 | 218,588 |
| | 2,200,521 | 9,088,152 | 2,194,313 | 9,033,986 |
| ប្រាក់កក់ | 74,460 | 307,520 | 71,498 | 294,357 |
| ប្រាក់បង់មុន | 2,491 | 10,288 | 32,207 | 132,596 |
| ផ្សេងៗ | 76,255 | 314,932 | 72,700 | 299,307 |
| | 2,353,727 | 9,720,892 | 2,370,718 | 9,760,246 |

## 6. គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ (ត)

បម្រែបម្រួលនៃសំវិធានធនលើឱនភាពនៃតម្លៃ សម្រាប់គណនីអតិថិជនក្នុងអំឡុងការិយបរិច្ឆេទ មានដូចខាងក្រោម៖

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ | | | | សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ ដែលបានបញ្ចប់ | | | |
|---|---|---|---|---|---|---|---|---|
| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 | | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| | | | *(មិនត្រូវបានត្រួតពិនិត្យ)* | | | | *(មិនត្រូវបានត្រួតពិនិត្យ)* | |
| សមតុល្យដើមការិយបរិច្ឆេទ | (101,172) | (416,525) | (82,013) | (334,121) | (94,427) | (382,807) | (91,574) | (370,875) |
| ទទួលស្គាល់ក្នុងរបាយការណ៍ ចំណេញ ឬខាត | (14,399) | (58,950) | (6,854) | (27,827) | (21,144) | (86,775) | 2,707 | 10,980 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (1,833) | - | 259 | - | (7,726) | - | (1,794) |
| សមតុល្យចុងការិយបរិច្ឆេទ | (115,571) | (477,308) | (88,867) | (361,689) | (115,571) | (477,308) | (88,867) | (361,689) |

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

## 7. សន្និធិ

| | ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 4) |
| សម្ភារៈសម្រាប់ជួសជុលក្បាលរថភ្លើង | 66,556 | 274,875 | 62,812 | 258,597 |
| ឧបករណ៍ | 38,481 | 158,927 | 62,641 | 257,893 |
| ប្រេងឥន្ធនៈ | 15,115 | 62,425 | 12,292 | 50,606 |
| ប្រេងម៉ាស៊ូត | 35,392 | 146,169 | 51,257 | 211,025 |
| សម្ភារៈសម្រាប់ជួសជុលទូររថភ្លើង | 15,905 | 65,688 | 25,833 | 106,355 |
| | 171,449 | 708,084 | 214,835 | 884,476 |

## 8. ទ្រព្យ និងបរិក្ខារ

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ការកែលម្អផ្លូវដែក និងស្ថានីយ៍<br>ដុល្លារអាមេរិក | ក្បាលរថភ្លើង<br>ដុល្លារអាមេរិក | ទូរថភ្លើង<br>ដុល្លារអាមេរិក | ផ្លូវរថភ្លើង<br>ដុល្លារអាមេរិក | ត្រូឡេ<br>ដុល្លារអាមេរិក | បរិក្ខារ និងគ្រឿងម៉ាស៊ីន<br>ដុល្លារអាមេរិក | បរិក្ខារការិយាល័យ<br>ដុល្លារអាមេរិក | គ្រឿងសង្ហារិម និងគ្រឿងបំពាក់<br>ដុល្លារអាមេរិក | បរិក្ខារព័ត៌មានវិទ្យា<br>ដុល្លារអាមេរិក | ស្លាកសញ្ញា និងរបាំងផ្លូវរថភ្លើង<br>ដុល្លារអាមេរិក | ទ្រព្យកំពុងបង្កើត<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក | សរុប<br>សមមូលពាន់រៀល<br>(កំណត់សម្គាល់ 4) |
| **ថ្លៃដើម** | | | | | | | | | | | | | |
| សមតុល្យដើមការិយបរិច្ឆេទ | 656,825 | 7,806,896 | 1,211,498 | 580,845 | 32,163 | 736,078 | 9,134 | 8,794 | 97,661 | 15,057 | 160,672 | 11,315,623 | 46,586,419 |
| ការទិញបន្ថែម | 10,882 | 293,739 | - | 11,842 | 9,270 | 43,159 | - | - | 4,129 | - | 953,745 | 1,326,766 | 5,431,780 |
| ការផ្ទេរ | 80,635 | 92,992 | 24,477 | 79,115 | - | 1,850 | - | - | - | - | (279,069) | - | - |
| ការផ្ទេរទៅទ្រព្យវិនិយោគ | - | - | - | - | - | - | - | - | - | - | (36,996) | (36,996) | (151,462) |
| ការផ្ទេរពីសន្និធិ | - | - | 119,287 | - | - | - | - | - | - | - | 9,928 | 129,215 | 529,006 |
| ការលុបចោល | (61,699) | (7,068) | (3,800) | (6,689) | - | (5,772) | - | - | - | - | (348) | (85,376) | (349,529) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | - | - | 195,114 |
| សមតុល្យចុងការិយបរិច្ឆេទ | 686,643 | 8,186,559 | 1,351,462 | 665,113 | 41,433 | 775,315 | 9,134 | 8,794 | 101,790 | 15,057 | 807,932 | 12,649,232 | 52,241,328 |
| ដកៈ **រំលស់បង្គរ** | | | | | | | | | | | | | |
| សមតុល្យដើមការិយបរិច្ឆេទ | 493,849 | 2,058,562 | 717,830 | 281,832 | 32,163 | 625,441 | 8,135 | 8,794 | 72,868 | 8,218 | - | 4,307,692 | 17,734,767 |
| រំលស់ក្នុងការិយបរិច្ឆេទ | 37,050 | 359,733 | 88,842 | 58,620 | 154 | 39,304 | 384 | - | 6,515 | 1,506 | - | 592,108 | 2,424,090 |
| ការលុបចោល | (47,870) | (6,855) | (3,800) | (3,836) | - | (5,729) | - | - | - | - | - | (68,090) | (278,760) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | - | - | 74,865 |
| សមតុល្យចុងការិយបរិច្ឆេទ | 483,029 | 2,411,440 | 802,872 | 336,616 | 32,317 | 659,016 | 8,519 | 8,794 | 79,383 | 9,724 | - | 4,831,710 | 19,954,962 |
| **តម្លៃយោង** | | | | | | | | | | | | | |
| សមតុល្យដើមការិយបរិច្ឆេទ | 162,976 | 5,748,334 | 493,668 | 299,013 | - | 110,637 | 999 | - | 24,793 | 6,839 | 160,672 | 7,007,931 | 28,851,652 |
| សមតុល្យចុងការិយបរិច្ឆេទ | 203,614 | 5,775,119 | 548,590 | 328,497 | 9,116 | 116,299 | 615 | - | 22,407 | 5,333 | 807,932 | 7,817,522 | 32,286,366 |

គិតត្រឹមថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 ទ្រព្យ និងបរិក្ខារ ដែលបានរំលស់ពេញលេញ និងមានថ្លៃដើមចំនួន 1,280,078 ដុល្លារអាមេរិក (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2022៖ ចំនួន 1,185,572 ដុល្លារអាមេរិក) គឺនៅតែបន្តប្រើប្រាស់នៅឡើយ។

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)**
**សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023**

## 8. ទ្រព្យ និងបរិក្ខារ (ត)

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2022 (មិនត្រូវបានត្រួតពិនិត្យ) | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ការកែលម្អផ្លូវដែក និងស្ថានីយ៍ ដុល្លារអាមេរិក | ក្បាលរថភ្លើង ដុល្លារអាមេរិក | ទូរថភ្លើង ដុល្លារអាមេរិក | ផ្លូវរថភ្លើង ដុល្លារអាមេរិក | គ្រូទ្បេ ដុល្លារអាមេរិក | បរិក្ខារ និង គ្រឿងម៉ាស៊ីន ដុល្លារអាមេរិក | បរិក្ខារ ការិយាល័យ ដុល្លារអាមេរិក | គ្រឿងសង្ហារិម និង គ្រឿងបំពាក់ ដុល្លារអាមេរិក | បរិក្ខារ ព័ត៌មានវិទ្យា ដុល្លារអាមេរិក | ស្លាកសញ្ញា និងរបាំងផ្លូវរថភ្លើង ដុល្លារអាមេរិក | ទ្រព្យកំពុងបង្កើត ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **ថ្លៃដើម** | | | | | | | | | | | | | |
| សមតុល្យដើមការិយបរិច្ឆេទ | 608,191 | 6,807,161 | 963,271 | 430,319 | 32,163 | 686,008 | 8,591 | 8,794 | 77,673 | 14,496 | 92,085 | 9,728,752 | 39,634,935 |
| ការទិញបន្ថែម | 2,505 | 86,705 | 19,742 | 14,009 | - | 40,747 | - | - | 11,159 | 561 | 1,079,870 | 1,255,298 | 5,096,510 |
| ការផ្ទេរ | 16,403 | 102,731 | 83,016 | 65,220 | - | - | - | - | 5,634 | - | (273,004) | - | - |
| ការលុបចោល | (750) | (12,890) | (1,352) | - | - | (17,953) | - | - | (2,772) | - | - | (35,717) | (145,011) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | - | - | (26,719) |
| សមតុល្យចុងការិយបរិច្ឆេទ | 626,349 | 6,983,707 | 1,064,677 | 509,548 | 32,163 | 708,802 | 8,591 | 8,794 | 91,694 | 15,057 | 898,951 | 10,948,333 | 44,559,715 |
| ដកៈ **រំលស់បង្គរ** | | | | | | | | | | | | | |
| សមតុល្យដើមការិយបរិច្ឆេទ | 454,968 | 1,563,136 | 595,800 | 179,184 | 32,163 | 574,709 | 6,818 | 8,740 | 62,996 | 5,234 | - | 3,483,748 | 14,192,789 |
| រំលស់ក្នុងការិយបរិច្ឆេទ | 36,693 | 284,017 | 65,562 | 48,052 | - | 40,863 | 810 | 27 | 6,109 | 1,478 | - | 483,611 | 1,963,461 |
| ការលុបចោល | (750) | (12,890) | (1,352) | - | - | (17,953) | - | - | (2,772) | - | - | (35,717) | (145,011) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | - | - | (9,456) |
| សមតុល្យចុងការិយបរិច្ឆេទ *(មិនត្រូវបានត្រួតពិនិត្យ)* | 490,911 | 1,834,263 | 660,010 | 227,236 | 32,163 | 597,619 | 7,628 | 8,767 | 66,333 | 6,712 | - | 3,931,642 | 16,001,783 |
| **តម្លៃយោង** | | | | | | | | | | | | | |
| សមតុល្យចុងការិយបរិច្ឆេទ | 135,438 | 5,149,444 | 404,667 | 282,312 | - | 111,183 | 963 | 27 | 25,361 | 8,345 | 898,951 | 7,016,691 | 28,557,932 |

# វ៉ូយ៉ាល់ គេលខេ ម.ក.

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ 3ខែ និង 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023

## 9. ទ្រព្យសកម្មអរូបី

| | សម្រាប់ដំណាច់ការិយបរិច្ឆេទ 6ខែ ដែលបានបញ្ចប់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2023 | | | |
|---|---|---|---|---|
| | សូហ្វវែរ កុំព្យូទ័រ | ប្រាក់កម្រៃលើ ការចុះហត្ថលេខា | សរុប | |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | សមមូលពាន់រៀល (កំណត់សម្គាល់ 4) |
| **ថ្លៃដើម** | | | | |
| សមតុល្យដើមការិយបរិច្ឆេទ | 19,090 | 450,000 | 469,090 | 1,931,244 |
| ការទិញបន្ថែម | 1,200 | - | 1,200 | 4,913 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 6,141 |
| សមតុល្យចុងការិយបរិច្ឆេទ | 20,290 | 450,000 | 470,290 | 1,942,298 |
| ដកៈ **រំលស់បង្គរ** | | | | |
| សមតុល្យដើមការិយបរិច្ឆេទ | 17,349 | 192,120 | 209,469 | 862,384 |
| រំលស់ក្នុងការិយបរិច្ឆេទ | 758 | 7,736 | 8,494 | 34,774 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | 3,029 |
| សមតុល្យចុងការិយបរិច្ឆេទ | 18,107 | 199,856 | 217,963 | 900,187 |
| **តម្លៃយោង** | | | | |
| សមតុល្យដើមការិយបរិច្ឆេទ | 1,741 | 257,880 | 259,621 | 1,068,860 |
| សមតុល្យចុងការិយបរិច្ឆេទ | 2,183 | 250,144 | 252,327 | 1,042,111 |

